មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

កំណត់ត្រាសន្ទនា

បរាជ័យនៃយន្តការដោះស្រាយទំនាស់ដីធ្លី

រាជធានីភ្នំពេញ ខែកក្កដា ឆ្នាំ២០១៤

ខ្លឹមសារសន្ទនា

កំណត់ត្រាសង្ខេបនេះពិនិត្យមើលទៅលើបច្ចុប្បន្នភាព និងការអនុវត្តយន្តការដោះស្រាយទំនាស់ដីធ្លីនៅក្នុងព្រះរាជាណាចក្រកម្ពុជា(“កម្ពុជា”)ដែលបានបង្កើតឡើងដើម្បីដោះស្រាយទំនាស់ដីធ្លី និងជម្លោះដែលកើតឡើងដោយសារសម្បទានដីសេដ្ឋកិច្ច និងការចាប់ច្បាមយកដីធ្លីរបស់ជនមានអំណាច និងក្រុមហ៊ុននានា។ ផ្នែកដំបូងនៃកំណត់ត្រាសង្ខេបនេះបង្ហាញសេចក្តីផ្តើមពីការរំលោភបំពានលើសិទ្ធិដីធ្លីនៅក្នុងបរិបទនៃសម្បទានដីសេដ្ឋកិច្ច និងការចាប់ច្បាមយកដីធ្លី ហើយនិងពិភាក្សាពីភាពទាក់ទងគ្នាដើម្បីសិក្សាពីយន្តការដោះស្រាយទំនាស់ដីធ្លីនៅកម្ពុជា។ ផ្នែកទីពីរលើកឡើងពីទិដ្ឋភាពទូទៅនៃយន្តការដោះស្រាយទំនាស់សំខាន់ៗចំនួន ៥ និងយុត្តាធិការនៃយន្តការនីមួយៗអាស្រ័យតាមប្រភេទនៃទំនាស់ដីធ្លីដែលពាក់ព័ន្ធ។ ផ្នែកទីបី ពិភាក្សាពីគម្លាតរវាងទ្រឹស្តី និងការអនុវត្តយន្តការដោះស្រាយទំនាស់នៅកម្ពុជាអមជាមួយករណីសិក្សាចំនួនពីរដើម្បីបង្ហាញពីកង្វះប្រសិទ្ធភាពនៃយន្តការដោះស្រាយទំនាស់ដែលមានស្រាប់។ ផ្នែកចុងក្រោយធ្វើសេចក្តីសន្និដ្ឋានដោយផ្តល់ជូននូវកម្រងអនុសាសន៍របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (“ម.ស.ម.ក”) ដើម្បីពង្រឹងការទទួលបានដំណោះស្រាយនិងការអនុវត្តយន្តការដោះស្រាយទំនាស់អោយកាន់តែទូលំទូលាយក្នុងការពង្រឹងការទទួលបានយុត្តិធម៌សម្រាប់សហគមន៍ដែលងាយរងគ្រោះនៅកម្ពុជា។ កម្រងអនុសាសន៍ទាំងនោះរួមមាន ៖

១. លើកកម្ពស់ការយល់ដឹងជាសាធារណៈជុំវិញយន្តការ និងភារកិច្ចដោះស្រាយវិវាទ ព្រមទាំងការទទួលខុសត្រូវរបស់គណៈកម្មការសុរិយោដីនៅទូទាំងប្រទេស។
២. បង្កើតនីតិវិធីជ្រើសរើសប្រកបដោយតម្លាភាពដើម្បីសម្រាំងយកអ្នកធ្វើសេចក្តីសម្រេចទៅលើដំណោះស្រាយទំនាស់។
៣. ព្រងគោលនយោបាយស្តីពីទំនាស់ផលប្រយោជន៍ និងដាក់ចេញឱ្យអនុវត្តន៍មុនការតែងតាំងសមាជិកថ្មីសម្រាប់ស្ថាប័នដោះស្រាយទំនាស់។

កំណត់ត្រាសង្ខេបនេះ គឺតាក់តែងឡើងដោយ ម.ស.ម.ក ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅទូទាំងប្រទេសកម្ពុជា។

សេចក្តីផ្តើម

នៅបច្ចុប្បន្ននេះ ការរំលោភ និងការបំពារបំពានលើសិទ្ធិដីធ្លី គឺជាការរំលោភបំពានសិទ្ធិមនុស្សដ៏រាលដាលជាងគេនៅកម្ពុជា។ បើទោះជាមានការការពារលើសិទ្ធិដីធ្លីចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ជាតិ និងច្បាប់អន្តរជាតិនោះក្តី ក៏សហគមន៍នានាបន្តរងគ្រោះដោយសារការចាប់ច្បាមយកដីធ្លីដោយខុសច្បាប់ និងយ៉ាងអយុត្តិធម៌។ ដីធ្លីនេះតែងត្រូវបានរដ្ឋាភិបាលប្រគល់ទៅឱ្យជនមានអំណាច ឬក្រុមហ៊ុននានាដើម្បីបង្កើតអាជីវកម្ម ឬពាណិជ្ជកម្ម ដែលជាញឹកញាប់មានការរំលោភដ៏ច្បាស់ក្រឡែតទៅលើក្របខ័ណ្ឌច្បាប់កម្ពុជា និងកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់កម្ពុជា។ ឧទាហរណ៍ ក្រុមហ៊ុនកសិពាណិជ្ជកម្ម ជារឿយៗស្ថិតនៅពីក្រោយការចាប់ច្បាមយកដីធ្លី ការបណ្តេញសហគមន៍តាមជនបទដោយបង្ខំដើម្បីបើកផ្លូវដល់ក្រុមហ៊ុនដាំកៅស៊ូ ឬចំការអំពៅ។ ដីធ្លីក៏ត្រូវបានរដ្ឋាភិបាលធ្វើអនុប្បយោគសម្រាប់សាងសង់ទំនប់វារីអគ្គិសនីផងដែរ ដែលនេះជាការបន្ថែមទៅលើការបន្លាស់ទីសហគមន៍ ដែលបានធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន និងសេដ្ឋកិច្ចរយៈពេលយូរអង្វែងលើតំបន់ដែលរងផលប៉ះពាល់។

សម្បទានដីសេដ្ឋកិច្ច គឺជាសិទ្ធិស្របច្បាប់បង្កើតឡើងតាមឯកសារផ្លូវការដែលរាជរដ្ឋាភិបាលកម្ពុជា (“រដ្ឋាភិបាល”) ផ្តល់ជូនទៅឱ្យបុគ្គលមួយរូប ក្រុមបុគ្គល ឬអង្គភាពណាមួយដើម្បីកាន់កាប់ និងធ្វើការអភិវឌ្ឍទៅលើដីឯកជនរបស់រដ្ឋ។ [1] សិទ្ធិទទួលបានសម្បទានដីសេដ្ឋកិច្ច គឺជាប្រធានបទនៃការរឹតត្បិតជាច្រើនដែលកំណត់ដោយច្បាប់ភូមិបាលឆ្នាំ ២០០១ (“ច្បាប់ភូមិបាល”) ពាក់ព័ន្ធទៅនឹងអនុក្រឹត្យ និងចិរវេលាកិច្ចសន្យាសម្បទានដាក់លាក់។

នៅខែធ្នូ ឆ្នាំ២០១២ រដ្ឋាភិបាលបានផ្តល់ ឬបានបម្រុងទុកផ្ទៃដីទំហំ ២,៦០០,០០០ ហិកតាទៅឱ្យក្រុមហ៊ុនឯកជនក្រោមរូបភាពសម្បទានដីសេដ្ឋកិច្ច ដែលបង្ហាញតួលេខកើនឡើង ១៦,៧% ចាប់ពីឆ្នាំ ២០១១។[2] ប្រជាពលរដ្ឋប្រមាណ ៧០០,០០០នាក់បានរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារសម្បទានដីសេដ្ឋកិច្ចដោយប្រឈមនឹងការបណ្តេញចេញដោយបង្ខំ និង/ឬប្តូរលំនៅដ្ឋានដោយពុំស្ម័គ្រចិត្ត។[3] ភាគច្រើននៃករណីទាំងនេះ អាជ្ញាធរខេកខានក្នុងការគោរពទៅតាមច្បាប់ភូមិបាល និងអនុក្រឹត្យឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច រួមទាំងពុំបានបើកឱ្យមានការពិគ្រោះយោបល់ជាសាធារណៈនិងផ្តល់សំណងដល់សហគមន៍ដែលរងគ្រោះ ព្រមទាំងខកខានធ្វើការវាយតម្លៃពីផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម។ លក្ខខណ្ឌតម្រូវថ្នាក់ជាតិ និងអន្តរជាតិអំពីការបណ្តេញចេញ និងការតាំងទីលំនៅក៏មិនត្រូវបានអនុវត្តតាមផងដែរ។[4] ការកំណត់ពីការគ្រប់គ្រងលើទំហំដី និងម្ចាស់កម្មសិទ្ធិលើសម្បទានដីសេដ្ឋកិច្ច មិនត្រូវបានអនុវត្តឱ្យបានត្រឹមត្រូវនោះទេ។ [5] សម្បទានដីសេដ្ឋកិច្ច

---

[1] ច្បាប់ភូមិបាល មាត្រា ៤៨។

[2] អាដហុក “ចំណុចផ្លាស់ប្តូរសំខាន់ សិទ្ធិដីធ្លី លំនៅដ្ឋាន និងធនធានធម្មជាតិនៅកម្ពុជា នៅឆ្នាំ២០១២” (ខែកុម្ភៈ ឆ្នាំ២០១២) អាចរកបានតាម ៖ http://bit.ly/1uh9EMS (“អាដហុក៖ ចំណុចផ្លាស់ប្តូរសំខាន់”)។

[3] អង្គការឃ្លាំមើលសិទ្ធិមនុស្ស “កម្ពុជា៖ យុទ្ធនាការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីឈានទៅរកការរំលោភបំពាន (ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០១៣) អាចរកបានតាម ៖ http://bit.ly/17FLZsD។

[4] អាដហុក៖ ចំណុចផ្លាស់ប្តូរសំខាន់

[5] អ្នកតំណាងពិសេសរបស់អគ្គលេខាធិការទទួលបន្ទុកផ្នែកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា “ សម្បទានដីសេដ្ឋកិច្ចនៅកម្ពុជា៖ ទស្សនៈវិស័យអំពីសិទ្ធិមនុស្ស” (ខែមិថុនា ឆ្នាំ២០០៧) អាចរកបានតាម៖http://bit.ly/1jXfNpz។

ត្រូវបានរដ្ឋាភិបាលផ្តល់ទៅឱ្យក្រុមហ៊ុនលើតំបន់ដីព្រៃអភិរក្ស[6] ជាការផ្ទុយទៅនឹងច្បាប់ស្តីពីព្រៃឈើ។ បើទោះជាមានការរំលោភបំពានទាំងនេះក្តី ក៏គ្មានប្រព័ន្ធត្រួតពិនិត្យលើសម្បទានដីនោះឡើយ។ ជាងនេះទៅទៀត យន្តការដោះស្រាយទំនាស់មិនបានលើកកម្ពស់ដល់សិទ្ធិរបស់សហគមន៍រងគ្រោះ និងមិនបានគោរពច្បាប់ ជាមួយគ្នានេះក៏មិនបានឱ្យជនមានអំណាច ឬក្រុមហ៊ុនទទួលខុសត្រូវចំពោះសកម្មភាពរបស់ពួកគេនោះឡើយ។

ក្នុងហានៈកម្ពុជាជាទីផ្សារកំពុងតែរីកលូតលាស់ ទីផ្សារនេះត្រូវបានរដ្ឋាភិបាលគ្រប់គ្រងលើសលប់ ដោយបានខិតខំបង្កើនការនាំចេញ និងធ្វើអាជីវកម្មលើធនធានធម្មជាតិក្នុងគោលបំណងអភិវឌ្ឍជាតិ។ ព្រោះ ហេតុនេះហើយ ការផ្តល់សម្បទានដីសេដ្ឋកិច្ចដ៏ធំធេងបានឈានទៅដល់ការបំផ្លិចបំផ្លាញបរិស្ថានការផ្លាស់ទីលំនៅរបស់សហគមន៍ដែលពឹងផ្អែកលើដីធ្លី និងធនធានធម្មជាតិដើម្បីចិញ្ចឹមជីវិត។ ការចាប់ច្បាមយកដីធ្លីក៏បានរំខានដល់ការរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងទីក្រុងផងដែរ ដោយមានផលប៉ះពាល់អវិជ្ជមានដល់ការចិញ្ចឹមជីវិត សកម្មភាពបង្កើតប្រាក់ចំណូល ការអប់រំ និងការទទួលបានសេវាសំខាន់ៗនានា ដូចជា ទឹកស្អាត អនាម័យ និងការថែទាំសុខភាព។ ឧទាហរណ៍ នៅរាជធានីភ្នំពេញតែមួយ កាលពីខែឧសភា ឆ្នាំ២០១១ មានប្រជាពលរដ្ឋយ៉ាងហោច ៣០,០០៩ គ្រួសារត្រូវបានបណ្តេញចេញពីលំនៅដ្ឋានរបស់ខ្លួន។[7] ទំនាស់ដីធ្លីទ្រង់ទ្រាយធំបាននាំឱ្យមានបាតុកម្មជាច្រើនព្រមទាំងទទួលការរិះគន់ពីបណ្តាសហគមន៍ អង្គការជាតិ និងអន្តរជាតិ។[8]

តាមការលើកឡើងនៅក្នុងកំណត់ត្រាសង្ខេបនេះ មានប្រជាពលរដ្ឋចំនួនតិចតួចបានជ្រាប ឬមានមធ្យោបាយទទួលបានយន្តការ ដែលតាមទ្រឹស្តី ស្ថាប័នទាំងនោះបង្កើតឡើងដើម្បីការពារសិទ្ធិដីធ្លីរបស់ប្រជាពលរដ្ឋ។ ឥទ្ធិពលមិនស្មើភាពគ្នារវាងភាគីពាក់ព័ន្ធក្នុងទំនាស់ដីធ្លី ដោយរួមទាំងកង្វះប្រព័ន្ធតុលាការឯករាជ្យ បន្តរារាំងជាច្រើនដល់ប្រជាពលរដ្ឋកម្ពុជាក្នុងការទទួលបានដំណោះស្រាយតាមផ្លូវច្បាប់ប្រកបដោយប្រសិទ្ធភាពក្នុងករណីពាក់ព័ន្ធនឹងសម្បទានដីសេដ្ឋកិច្ច ការចាប់ច្បាមយកដីធ្លី ការបណ្តេញចេញដោយបង្ខំ និងការផ្លាស់ទីលំនៅ។[9]

ទិដ្ឋភាពទូទៅដុំពិញ្ញយន្តការដោះស្រាយទំនាស់

ការដោះស្រាយទំនាស់ដីធ្លី គឺអាស្រ័យថាតើដីនោះបានចុះបញ្ជី ឬមិនទាន់បានចុះបញ្ជី មានយន្តការដោះស្រាយទំនាស់ចំនួន ៥ ដើម្បីដោះស្រាយជម្លោះពាក់ព័ន្ធនឹងដីធ្លីចាប់តាំងពីការចាប់យកដីធ្លី និងសម្បទានដីសេដ្ឋកិច្ច រួមមាន៖ ១) ក្រុមប្រឹក្សាឃុំ/សង្កាត់ ២) គណៈកម្មការរដ្ឋបាល ៣)គណៈកម្មាធិការសុរិយោដី ៤) អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និង ៥) ប្រព័ន្ធតុលាការ។

---

[6] សុរិយាស៊ូប៊ែឌី "របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ផ្នែកបន្ថែម៖ ការវិភាគអំពីសិទ្ធិមនុស្សជុំវិញសេដ្ឋកិច្ច និងសម្បទានដីដទៃៗទៀតនៅកម្ពុជា" ក/គ.ស.ម/២១/៦៣/បន្ថែម ១/ដំណោះស្រាយ១(ថ្ងៃទី១០ ខែតុលាឆ្នាំ២០១២) អាចរកបានតាមរយៈ: http://bit.ly/17FL8bq ("របាយការណ៍ឆ្នាំ២០១២") ទំព័រ ៣៨។

[7] អាដហុក៖ ចំណុចផ្លាស់ប្តូរសំខាន់

[8] របាយការណ៍សង្ខេបរបស់ ម.ស.ម.ក ស្តីពី ការឃ្លាំមើលសម្បទានដីក្នុងឆ្នាំ២០១២ រាជធានីភ្នំពេញ (ខែកុម្ភៈ ឆ្នាំ២០១៣) អាចរកបានតាមរយៈ ៖ http://bit.ly/1ngSZJH។

[9] របាយការណ៍សិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋាននៅកម្ពុជាឆ្នាំ២០០៩ ដីធ្លី និងក្រុមការងារលំនៅឋាន កម្ពុជា (ខែមេសា ឆ្នាំ២០០៩) អាចរកបានតាមរយៈ ៖ http://bit.ly/1jwnkA3។

ក្រុមប្រឹក្សាឃុំ/សង្កាត់ "ជាអ្នកប្រមូលគំនិតយោបល់ផ្សេងៗ" របស់ប្រជាពលរដ្ឋក្នុងឃុំ/សង្កាត់ ប៉ុន្តែគ្មានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចនោះទេ។ [10] នៅពេលគ្មានសេចក្តីសម្រេចជាមុន តាមការអនុវត្តជាក់ស្តែងករណីភាគច្រើនគ្រាន់តែធ្វើសវនកម្មនៅមុខក្រុមប្រឹក្សាឃុំ/សង្កាត់ មុនពេលបញ្ជូនបន្តទៅថ្នាក់លើ។[11]ក្រុមប្រឹក្សារដ្ឋបាលធ្វើប្រតិបត្តិការនៅគ្រប់តំបន់នានា ហើយករណីដំបូងកើតឡើងក្នុងអំឡុងពេលយុទ្ធនាការចុះបញ្ជីដីធ្លីឧបត្ថម្ភដោយរដ្ឋាភិបាល។ [12] ទោះបីជាក្រុមប្រឹក្សារដ្ឋបាលពុំមានអំណាចចេញសេចក្តីសម្រេចចងកាតព្វកិច្ចក្តី ក៏អាចជួយភាគីមានជម្លោះក្នុងការដោះស្រាយទំនាស់នោះបានផងដែរ។[13]

<u>គណៈកម្មាធិការសុរិយោដីធ្លី</u>

កម្មវិធីគ្រប់គ្រង និងរៀបចំដីធ្លី ដែលបានចាប់ផ្តើមឡើងនៅក្នុងឆ្នាំ២០០២ គឺជាដំណាក់កាលដំបូងនៃការរៀបចំ ការគ្រប់គ្រង និងការបែងចែកដីធ្លីរបស់រដ្ឋាភិបាល។ កម្មវិធីនេះដំបូងឡើយមានគម្រោងអនុវត្តរយៈពេល១៥ឆ្នាំ និងបានដាក់ចេញនូវទិសដៅសំខាន់ៗមួយចំនួន រួមទាំងការទប់ស្កាត់ និងដោះស្រាយទំនាស់ដីធ្លីនានាផង។ ប៉ុន្តែធនាគារពិភពលោកជាដៃគូរអភិវឌ្ឍដ៏សំខាន់មួយជាមួយកម្មវិធីនេះ បានចេញសេចក្តីថ្លែងការណ៍មួយនៅឆ្នាំ២០០៩ ថា កម្មវិធីគ្រប់គ្រង និងរៀបចំដីធ្លីមិនបានសម្រេចលទ្ធផលតាមការគ្រោងទុកនោះទេជា–ពិសេសសំដៅដល់កិច្ចការពារផ្នែកសង្គម និងបរិស្ថាននៅតាមតំបន់ទំនាស់នានាក្នុងទីក្រុង។[14]ព្រោះហេតុដូច្នោះរដ្ឋាភិបាលបានសម្រេចបញ្ចប់ភាពជាដៃគូរក្នុងកម្មវិធីគ្រប់គ្រង និងរៀបចំដីធ្លីជាមួយធនាគារពិភពលោក ដែលនាំឱ្យមានការបញ្ចប់ការផ្តល់ថវិការបស់ធនាគារពិភពលោកដល់គម្រោងនេះ។

ការគួរឱ្យកត់សម្គាល់នោះ គឺសមាសភាគចំនួនបួននៃកម្មវិធីគ្រប់គ្រង និងរៀបចំដីធ្លីផ្តោតសំខាន់លើការបង្កើនសមត្ថភាពស្ថាប័នរដ្ឋាភិបាលក្នុងការដោះស្រាយទំនាស់ដីធ្លី ពោលគឺតាមរយៈការបង្កើតយន្តការដោះស្រាយទំនាស់បីថ្នាក់នៃគណៈកម្មាធិការសុរិយោដី។ ច្បាប់ភូមិបាលណែនាំថា ជម្លោះកើតឡើងលើដីធ្លីដែលមិនទាន់បានចុះបញ្ជីត្រូវបញ្ជូនទៅគណៈកម្មាធិការសុរិយោដីដើម្បីធ្វើការស៊ើបអង្កេត និងដោះស្រាយ។ [15] គណៈ–កម្មាធិការសុរិយោដីត្រូវបានគេរំពឹងថានឹងផ្តល់នូវមធ្យោបាយដោះស្រាយករណីវិវាទនោះទាន់ពេលវេលា ដោយពុំមានការចំណាយ និងមានការជំទាស់តិចតួច។

---

[10] អនុក្រឹត្យលេខ ២២ កណដ/ខដ ស្តីពី វិមជ្ឈការនៃអំណាច តួនាទី និងករណីកិច្ចរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ ថ្ងៃទី២៥ ខែមីនា ឆ្នាំ ២០០២ មាត្រា ៦១។

[11] របាយការណ៍របស់អ្នកតំណាងពិសេស ឆ្នាំ២០១២។

[12] រដ្ឋាភិបាលបង្កើតកម្មវិធីចុះបញ្ជីដីធ្លីចំនួនពីរ គឺ ៖ ១) កម្មវិធីចុះបញ្ជីដីធ្លីជាលក្ខណៈប្រព័ន្ធ និង ២) កម្មវិធីចុះបញ្ជីដីធ្លីម្តងម្កាល។ ការចុះបញ្ជីដីធ្លីជាប្រព័ន្ធគឺផ្តួចផ្តើមឡើងដោយរដ្ឋាភិបាល ដែលកំណត់តំបន់មួយនៅពេលបានវាស់វែង និងផ្តល់ប័ណ្ណកម្មសិទ្ធិរួចហើយ និងមានគោលបំណងធ្វើឱ្យដីដែលពុំមានលក្ខណៈគ្រប់គ្រាន់តាមច្បាប់នោះជាដីស្របច្បាប់។

[13] សមាសភាព និងតួនាទីរបស់គណៈកម្មការគ្រប់គ្រងដីធ្លីមានចែងនៅក្នុងអនុក្រឹត្យលេខ ៤៦ កណដ/ ខដ ស្តីពីនីតិវិធីបង្កើតផែនទីឧបសម្ព័ន្ធសុរិយោដី និងបញ្ជីដីធ្លី ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២។

[14] ធនាគារពិភពលោក "សេចក្តីថ្លែងការណ៍របស់ធានាគារពិភពលោកស្តីពី ការបញ្ចប់គម្រោងគ្រប់គ្រង និងរៀបចំដីធ្លីរបស់ រដ្ឋាភិបាល" (ចេញផ្សាយនៅថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០០៩) អាចរកបានតាមរយៈ ៖ http://bit.ly/1bm0pQk។

[15] ច្បាប់ភូមិបាល អនុក្រឹត្យលេខ ៤៧ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសុរិយោដី ឆ្នាំ២០០២។

យន្តការដោះស្រាយទំនាស់ថ្នាក់ក្រោមចំនួនបី បានបង្កើតឡើងនៅក្រោមគណៈកម្មាធិការសុរិយោដី ដើម្បីធ្វើសវនកម្មទំនាស់នានាពាក់ព័ន្ធទៅនឹងដីធ្លីដែលមិនទាន់បានចុះបញ្ជី និងទំនាស់ដែលមិនទាន់បានដោះស្រាយនៅមុនក្រុមប្រឹក្សារដ្ឋបាល យន្តការទាំងនោះមាន ១) នៅថ្នាក់ស្រុក/ខណ្ឌ ២) ថ្នាក់ខេត្ត/ក្រុង និង ៣) នៅថ្នាក់ជាតិ។ ទំនាស់ដីធ្លីជាដំបូងត្រូវដោះស្រាយនៅថ្នាក់ស្រុក/ខណ្ឌ ដែលមានសមត្ថកិច្ចត្រឹមតែផ្តល់ការគាំទ្រឱ្យមានការផ្សះផ្សា។[16]ប្រសិនបើមិនអាចឈានដល់ការព្រមព្រៀងគ្នានៅថ្នាក់ស្រុក/ ខណ្ឌទេ ករណីនោះត្រូវបញ្ជូនទៅថ្នាក់ខេត្ត/ក្រុង ដើម្បីផ្សះផ្សាថែមទៀត។[17] ដោយហេតុថា នៅឆ្នាំ២០០៩ គណៈកម្មាធិការសុរិយោដីខេត្តទទួលបានប្រតិភូកម្មអំណាចឱ្យចេញសេចក្តីសម្រេចក្នុងករណីនានានៅពេលដែលដំណោះស្រាយមិនអាចទៅរួច។[18] នៅថ្នាក់ស្រុក/ខណ្ឌ និងថ្នាក់ខេត្ត/ក្រុង គណៈកម្មាធិការសុរិយោដីដឹកនាំដោយអភិបាលស្រុក/ ខណ្ឌ និងថ្នាក់ខេត្ត/ក្រុង។[19] ប្រសិនបើករណីនោះមិនអាចដោះស្រាយបាននៅថ្នាក់ស្រុក/ខណ្ឌ និងខេត្ត/ក្រុងនោះទេ ករណីវិវាទនោះនឹងត្រូវបញ្ជូនទៅកាន់គណៈកម្មាធិការសុរិយោដីថ្នាក់ជាតិដើម្បីធ្វើការវិនិច្ឆ័យ។[20]

យោងតាមរបាយការណ៍កាលពីខែកញ្ញា ឆ្នាំ២០១៣ របស់ទីភ្នាក់ងារផ្តល់ជំនួយអាលីម៉ង់ជីអាយហ្សេត (GIZ) បានឱ្យដឹងថា គណៈកម្មាធិការសុរិយោដីកំពុងដំណើរការដោះស្រាយករណីវិវាទដីធ្លីចំនួន ៥០០០ ករណី និងបានដោះស្រាយរួចរាល់ជាស្ថាពរ ២៥០០ករណី។ ក្នុងចំណោមករណីនោះ វិវាទចំនួន៤០០ករណីជាញឹកញាប់ទាក់ទិនទៅនឹងក្រុមអ្នកភូមិប្តឹងជំទាស់ទៅនឹងជនមានអំណាច។ [21] ជម្លោះដីធ្លីកំពុងកើនឡើង ហើយរបាយការណ៍លើកឡើងថាមានដំណោះស្រាយប្រហែលជា៥០ភាគរយ ចំណែកឯរបាយការណ៍របស់គណៈកម្មាធិការសុរិយោដីបង្ហាញពីចំណុចល្អប្រសើរ។

តុលាការ

តុលាការកម្ពុជាមានយុត្តាធិការទៅលើទំនាស់ដីណាដែលបានចុះបញ្ជី និងដីដែលបានផ្តល់ប័ណ្ណកម្មសិទ្ធិរួចហើយ។[22] ប្រសិនបើភាគីមិនពេញចិត្តអាចប្តឹងទៅសាលាឧទ្ធរណ៍បាន។ ភាគីដែលមិនពេញចិត្តនឹងសេ

---

[16] ប្រភពខាងលើ មាត្រា ៦។

[17] ប្រភពខាងលើ មាត្រា ១៥។

[18] ប្រកាសរបស់ MLMUPC ស្តីពីការធ្វើប្រតិភូកម្មអំណាចដល់អភិបាលនៃគណៈអភិបាលខេត្ត/ក្រុង ប្រធាន PMCC តាមការចេញសេចក្តីសម្រេចលើទំនាស់ដីធ្លីតាមយន្តការដោះស្រាយរបស់គណៈកម្មាធិការសុរិយោដី ថ្ងៃទី ២១ ខែមករា ឆ្នាំ២០១០ សារាចរណែនាំ របស់ MLMUPC លេខ១ ស្តីពីការអនុវត្តន៍នីតិវិធីសម្រេចលើករណីវិវាទដីធ្លីនៅគណៈកម្មាធិការសុរិយោដីថ្នាក់ខេត្ត/ក្រុង ថ្ងៃទី២១ ខែមករា ឆ្នាំ ២០១១។

[19]ធានាគារពិភពលោក មជ្ឈមណ្ឌលសម្រាប់ការសិក្សាស្រាវជ្រាវដាន់ខ្ពស់ និងដីអាយហ្សេត "តើឆ្ពោះទៅរកស្ថាប័នយុត្តិធម៌? ការត្រួតពិនិត្យទៅលើការងាររបស់គណៈកម្មាធិការសុរិយោដីនៅកម្ពុជាពាក់ព័ន្ធទៅនឹងដំណោះស្រាយទំនាស់ដីធ្លី" ទំព័រ ១២ (ខែតុលា ឆ្នាំ ២០០៦) អាចរកបានតាមរយៈ ៖ http://bit.ly/1n30yAW។

[20] ច្បាប់ភូមិបាល មាត្រា ១៦។

[21] ហ្វ្រាន វ៉ូលឃើ មូលរ៉ "កម្មវិធីសិទ្ធិដីធ្លី–សិទ្ធិកាន់កាប់ដីធ្លី និងការទទួលបានដីធ្លី–ដំណាក់សំខាន់ក្នុងការយល់ដឹងពីសិទ្ធិមនុស្ស សិទ្ធិទទួលបានចំណីហារ និងសិទ្ធិតាំងទីលំនៅ" ជីអាយហ្សេតកម្ពុជា (ខែកញ្ញា ឆ្នាំ២០១៣) អាចរកបានតាម៖ http://bit.ly/Uy9p3n។

[22] អនុក្រឹត្យលេខ ៤៧ ថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ និងប្រកាសស្តីពី ការណែនាំ និងនីតិវិធីរបស់គណៈកម្មាធិការសុរិយោដី ករណីលេខ១១២ យណដ/ខទដ មាត្រា ៣។

ចក្តីសម្រេចរបស់គណៈកម្មាធិការសុរិយោដីថ្នាក់ជាតិអាចប្តឹងបានផងដែរទៅសាលាឧទ្ធរណ៍។[23] តុលាការក៏មានយុត្តាធិការដែរទៅលើករណីពាក់ព័ន្ធនឹងការបណ្តេញចេញដោយបង្ខំ ព្រមទាំងកិច្ចសន្យា និងទំនាស់មរតកដោយ មិនគិតពីសណ្ឋានដីដែលបានចុះបញ្ជី និងដីដែលមិនបានចុះបញ្ជីនោះទេ។[24] ប្រសិនបើករណីនោះពាក់ព័ន្ធនឹងដីធ្លីដែលមិនទាន់ចុះបញ្ជី ភាគីត្រូវតែបញ្ជូនករណីនោះជាដំបូងទៅកាន់គណៈកម្មាធិការសុរិយោដី។

អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

នៅក្នុងខែមីនាឆ្នាំ២០០៦ មានព្រះរាជក្រឹត្យ[25] បង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី (“អាជ្ញាធរជាតិ”)។ ការបង្កើតអាជ្ញាធរជាតិនេះគឺធ្វើឡើងតាមរយៈព្រះរាជក្រឹត្យជាជាងច្បាប់ភូមិបាលបង្កើតដោយសភាដែលបង្កការលំបាកក្នុងការផ្សះផ្សាជាមួយនឹងស្ថាប័នដោះស្រាយទំនាស់ដីធ្លីដទៃៗទៀត។ ម្យ៉ាងវិញទៀត ការពុំបានចែងពីរបៀបអនុវត្តរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីក្នុងច្បាប់ភូមិបាល បានលើកជាមន្ទិលសង្ស័យជាខ្លាំងពីធម្មនុញ្ញភាពរបស់ស្ថាប័ននេះ។ [26] បច្ចុប្បន្ននេះ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីដឹកនាំដោយឧបនាយករដ្ឋមន្ត្រី[27]រួមទាំងសមាជិកសភា ទីប្រឹក្សារដ្ឋាភិបាល និងអ្នកច្បាប់។ អង្គការមិនមែនរដ្ឋាភិបាលត្រូវបានផ្តល់ឱកាសឱ្យតែងតាំងតំណាងមួយរូបចូលរួមក្នុងគណៈកម្មការនេះ តែពួកគេបានបដិសេធក្នុងការចូលរួមដោយសំអាងថា ពួកគេមិនចង់ពាក់ព័ន្ធជាមួយស្ថាប័ន ព្រោះខ្លួនពុំមានឥទ្ធិពលនោះទេ។[28]

សមាសភាពអនុប្រធាន រួមមានរដ្ឋមន្ត្រីក្រសួងដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច និងទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស។[29] អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមានអគ្គលេខាធិការដ្ឋានមួយដឹកនាំដោយរដ្ឋលេខាធិការនៅទីស្តីការគណៈរដ្ឋមន្ត្រី។[30]ការសិក្សាមួយបានរកឃើញថា ប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីបញ្ជូនកិច្ចការទាំងអស់ទៅនាយករដ្ឋមន្ត្រីដើម្បីធ្វើសេចក្តីសម្រេចចុងក្រោយ។ សមាសភាពរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីបង្ហាញថាខ្លួនត្រូវបានគ្រប់គ្រងទាំងស្រុងដោយមន្ត្រី ឬសមាជិករបស់រដ្ឋាភិបាលដែលជាការគំរាមធ្ងន់ធ្ងរដល់ឯករាជ្យភាព

---

[23] ច្បាប់ភូមិបាល មាត្រា ២៣។

[24] ក្រសួងយុត្តិធម៌ និង MLMUPC ប្រកាសរួមលេខ ៣ ស្តីពីការកំណត់សមត្ថកិច្ចរបស់តុលាការ និងគណៈកម្មាធិការសុរិយោដីទាក់ទិននឹងទំនាស់ដីធ្លី ថ្ងៃទី២៦ខែវិច្ឆិកា ឆ្នាំ២០០៣ មាត្រា ១ និងមាត្រា ៤។

[25] ព្រះរាជក្រឹត្យស្តីពី ការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកដោះស្រាយទំនាស់ដីធ្លី ណស/ជន/០២០៦/០៩៧ (ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ ២០០៦)។

[26] ដាំណែល អេដលើ “អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីកម្ពុជា៖ ការសិក្សាពិសេស” មជ្ឈមណ្ឌលដើម្បីការសិក្សាឈានមុខ និងជានាគារពិភពលោក យុត្តិធម៌សម្រាប់ប្រជាពលរដ្ឋក្រីក្រ (ខែមករា ឆ្នាំ២០០៨) អាចរកបានតាម៖http://bit.ly/T2yNwO ។

[27] ម៉ាយ ទិត្យថារា “ទំនាស់ដីធ្លីភាគច្រើននៅកម្ពុជាមិនត្រូវបានដោះស្រាយ” កាសែត *ភ្នំពេញប៉ុស្តិ៍*(ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣) អាចរកបានតាមរយៈ ៖ http://bit.ly/1nzKxPZ។

[28] របាយការណ៍របស់អ្នករាយការណ៍ពិសេស ឆ្នាំ២០១២។

[29] អនុក្រឹត្យលេខ១២២៧ ស្តីពីការរៀបចំនៃសមាភាពរបស់គណៈកម្មាធិការជាតិដោះស្រាយទំនាស់ដីធ្លី ខែវិច្ឆិកា ឆ្នាំ២០១១។

[30] ប្រភពខាងលើ។

និងភាពត្រឹមត្រូវនៃអាជ្ញាធរជាតិនេះ។ ការសិក្សាដដែលនេះបានរកឃើញផងដែរថា បុគ្គលិកនៅក្នុងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមានការស្ទាក់ស្ទើរក្នុងការផ្តល់ព័ត៌មានសំខាន់ៗដល់សាធារណៈជន។[31]

អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមានឥទ្ធិពលដោះស្រាយទំនាស់ដីធ្លីតាមរយៈកំណត់ថាតើភាគីណាមួយទទួលយក ហើយភាគីណាមួយត្រូវបញ្ជូនទៅស្ថាប័នដទៃទៀត (រួមទាំងតុលាការ) និងពីរបៀបដែលខ្លួនស៊ើបអង្កេត។ [32] សេចក្តីសម្រេចរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីអាចប្តឹងឧទ្ធរណ៍ទៅតុលាការបាន ដរាបណាសេចក្តីសម្រេចនោះអាចត្រូវកំណត់បាន សិទ្ធិនេះមិនត្រូវបានប្រើនោះទេ។[33]

អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីបំពេញមុខងារបន្ថែមដល់គណៈកម្មាធិការសុរិយោដី និងត្រូវបានផ្តល់សិទ្ធិឱ្យធ្វើសវនកម្មលើករណីទំនាស់ដីធ្លីនានាដែល "ផុតពីដែនយុត្តាធិការ" របស់គណៈកម្មាធិការសុរិយោដី។[34] ដោយហេតុថា ករណីទាំងនោះពាក់ព័ន្ធនឹងមន្ត្រីជាន់ខ្ពស់ ឬបុគ្គលមានឥទ្ធិពលដែលត្រូវបានបញ្ជូនមកកាន់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី អាជ្ញាធរនេះ ត្រូវបានគេរិះគន់ជុំវិញការអនុវត្តរំលងយុត្តាធិការដ៏ត្រឹមត្រូវរបស់គណៈកម្មាធិការសុរិយោដី និងតុលាការ។ ជាងនេះទៅទៀតនោះ អាណត្តិការងាររបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីត្រូវបានគេរិះគន់ថាមានភាពមិនច្បាស់លាស់ និងមានដែនសមត្ថកិច្ចហួសហេតុលើច្បាប់ភូមិបាល។

មានចន្លោះប្រហោងមួយចំនួនពាក់ព័ន្ធទៅនឹងការដាក់ពាក្យបណ្តឹងទៅអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី។ ជាដំបូងអ្នកប្តឹងត្រូវដាក់ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរដោយផ្ទាល់ទៅកាន់ការិយាល័យរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីក្នុងរាជធានីភ្នំពេញ។ លក្ខខណ្ឌតម្រូវបែបនេះធ្វើឱ្យលំបាកដល់ការទទួលបានយន្តការដោះស្រាយទំនាស់ធៀបទៅនឹងអាជ្ញាធរមូលដ្ឋាន គណៈកម្មាធិការសុរិយោដី និងតុលាការ។ ជាមួយគ្នានេះ ពាក្យបណ្តឹងនោះមិនតម្រូវឱ្យមានទម្រង់បែបបទជាក់លាក់នោះទេ ដោយត្រូវដាក់ភ្ជាប់ទៅជាមួយនូវឯកសារមួយចំនួនដូចជាអត្តសញ្ញាណប័ណ្ណ និងសៀវភៅគ្រួសារ។ក្នុងករណីបណ្តឹងសមូហភាព អ្នកប្តឹងត្រូវបញ្ជូនឯកសារបញ្ជាក់ថាពួកគាត់បានផ្ទេរសិទ្ធិរបស់ខ្លួនទៅឱ្យតំណាងមួយរូប។[35] ចន្លោះប្រហោងមួយទៀតរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីគឺពុំមានសំណុំបែបបទ ឬនីតិវិធីត្រឹមត្រូវ។ ដូច្នេះហើយ ការកំណត់ករណីទំនាស់ដែលត្រូវធ្វើសវនកម្មដោយអាជ្ញាធរជាតិ និងករណីដែលត្រូវបញ្ជូនទៅស្ថាប័នដទៃពេលបច្ចុប្បន្ននេះមិនត្រូវបានគេដឹងឮនៅឡើយទេ។ ជាងនេះទៀតមិនមានព័ត៌មានដាក់បង្ហាញជាសាធារណៈស្តីពីដំណើរការនៃការធ្វើសេចក្តីសម្រេចលើករណីទំនាស់ ឬការអនុវត្តនីតិវិធីនោះឡើយ។

---

[31] ដាណែល អេដលើ "អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីកម្ពុជា៖ ការសិក្សាពិសេស" មជ្ឈមណ្ឌលដើម្បីការសិក្សាស្រាវជ្រាវដាន់ខ្ពស់ និងធានាគារពិភពលោក យុត្តិធម៌សម្រាប់ប្រជាពលរដ្ឋក្រីក្រ (ខែមករា ឆ្នាំ២០០៨) អាចរកបានតាម ៖http://bit.ly/T2yNwO។

[32] ប្រភពខាងលើ។

[33] ប្រភពខាងលើ។

[34] ព្រះរាជក្រឹត្យ ណស/ទនដ/០២០៦/៦៩៧ មាត្រា ៣។

[35] ដាណែល អេដលើ "អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីកម្ពុជា៖ ការសិក្សាពិសេស" មជ្ឈមណ្ឌលដើម្បីការសិក្សាឈានមុខ និងធានាគារពិភពលោក យុត្តិធម៌សម្រាប់ប្រជាពលរដ្ឋក្រីក្រ (ខែមករា ឆ្នាំ២០០៨) អាចរកបានតាម៖http://bit.ly/T2yNwO។

យោងតាមអត្ថបទមួយចេញផ្សាយនៅលើកាសែត *ភ្នំពេញប៉ុស្ត៍* លើកឡើងពីរបាយការណ៍ប្រចាំឆ្នាំ ២០១២ របស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី[36] បានបង្ហាញថា មានបណ្តឹងតិចជាង៣០% ត្រូវបានដោះស្រាយនៅក្នុងឆ្នាំ២០១២។ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីបានដោះស្រាយទំនាស់ចំនួន១០៣ បណ្តឹង ក្នុងនោះបណ្តឹងចំនួន ៣០ គឺជាបណ្តឹងរបស់ប្រជាពលរដ្ឋ និងស្ថាប័ននានានៅតាមខេត្តចំនួន១៩។[37]អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមិនអាចបញ្ជាក់ពីចំនួនពិតប្រាកដនៃបណ្តឹងនាបច្ចុប្បន្នទេ។ប៉ុន្តែយ៉ាងណាក្តីតួលេខបានមកពីការសិក្សាពីមុនបានបង្ហាញថាពាក្យបណ្តឹងចំនួន ១៩៥៦ ត្រូវបានបញ្ជូនទៅកាន់អាជ្ញាធរជាតិ នៅចន្លោះពីខែមីនា និងតុលា ឆ្នាំ២០០៦។[38] ក្នុងចំណោមករណីចំនួន ១៩៥៦ ករណីចំនួន៥២៧ ត្រូវបានទទួលយក។ ក្នុងចំណោមករណីទាំងនេះ ករណីចំនួន១៥៣ ត្រូវបានបង្វែរទៅកាន់ក្រសួងយុត្តិធម៌ (ដើម្បីបញ្ជូនបន្តទៅតុលាការ) ករណីចំនួន១៣០ ត្រូវបានបង្វែរទៅកាន់គណៈកម្មាធិការសុរិយោដីថ្នាក់ជាតិ ករណីចំនួន ២៨ ត្រូវបានកំណត់ថាជាករណីស្ទួនគ្នាហើយមានករណីចំនួនតែ ៤ ប៉ុណ្ណោះត្រូវបានដោះស្រាយ។ នេះមិនប្រាកដទេថាហេតុអ្វីអាជ្ញាធរជាតិមិនទទួលដោះស្រាយករណីទំនាស់ដ៏ច្រើននេះ គឺចំនួន១៤២៩ ក្នុងចំណោមករណីចំនួន ១៩៥៦។ តែក៏មិនប្រាកដដែរថា ហេតុអ្វីអាជ្ញាធរជាតិទទួលដោះស្រាយករណីត្រឹមតែចំនួន២១២ ក្នុងចំណោម ៥២៧ករណី នេះបង្ហាញឱ្យឃើញថាការដោះស្រាយទំនាស់របស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីនៅមានកម្រិតទាប។[39]

ដោយហេតុថា អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីផុតពីដែនសមត្ថកិច្ចនៃច្បាប់ភូមិបាលនោះ អ្នករាយការណ៍ពិសេសសង្កេតឃើញថា *"នេះមិនមានកំណត់ច្បាស់លាស់ក្នុងក្របខ័ណ្ឌដែលមានស្រាប់នៃស្ថាប័នដោះស្រាយទំនាស់ដីធ្លី"* នោះទេ។[40]ជាងនេះទៅទៀតឥទ្ធិពលនយោបាយហួសហេតុ និងទំនាស់ផលប្រយោជន៍ ពិតជាកើតមានទៅលើករណីណាដែលសមាជិកជាន់ខ្ពស់ ឬមានឥទ្ធិពលរបស់រដ្ឋាភិបាលដែលត្រូវបានតែងតាំងដើម្បីដោះស្រាយទំនាស់ដីធ្លីពាក់ព័ន្ធនឹងបុគ្គលមានឥទ្ធិពលដទៃទៀត។[41][42] នៅពេលបច្ចុប្បន្ននេះ សិទ្ធិអំណាចយុត្តាធិការ និងរបាយការណ៍តាមដានរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីស្តីពីការដោះស្រាយទំនាស់នៅ

---

36 កាសែត *ភ្នំពេញប៉ុស្ត៍* "ករណីទំនាស់ដីធ្លីភាគច្រើននៅកម្ពុជាមិនត្រូវបានដោះស្រាយ" (ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣) អាចរកបានតាមរយៈ ៖ http://bit.ly/1nzKxPZ។

37 ប្រភពដូចខាងលើ។

ដាំណែល អេដលើ "អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីកម្ពុជា៖ ការសិក្សាពិសេស" មជ្ឈមណ្ឌលដើម្បីការសិក្សាឈានមុខ និងធនាគារពិភពលោក យុត្តិធម៌សម្រាប់ប្រជាពលរដ្ឋក្រីក្រ (ខែមករា ឆ្នាំ២០០៨) អាចរកបានតាម៖http://bit.ly/T2yNwO។

39 ប្រភពខាងលើ។

40 របាយការណ៍របស់អ្នករាយការណ៍ពិសេស ឆ្នាំ២០១២។

41 សិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋាននៅកម្ពុជា ព្រមទាំង របាយការណ៍ឆ្នាំ ២០០៩ ក្រុមការងារដីធ្លី និងលំនៅដ្ឋានកម្ពុជា (ខែមេសា ឆ្នាំ ២០០៩) អាចរកបានតាម៖ http://bit.ly/1jwnkA3។

42 ឡាវីណា ហ្វេដស្តាយ "យន្តការនៃការដោះស្រាយទំនាស់តាមតំបន់ជនបទក្នុងប្រទេសកម្ពុជា" (ថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០១០)អាចរកបានតាម៖ http://bit.ly/UgHGnX។

មិនទាន់ច្បាស់លាស់ និងមានព័ត៌មានតិចតួចពីដំណើរការដោះស្រាយរបស់ខ្លួនដាក់បង្ហាញដល់សាធារណៈជន។[43]

ដោយសារតែសក្តានុពលដ៏ខ្លាំងក្លារបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដី លើការបំពានអំណាច និងទំនាស់ផលប្រយោជន៍ ព្រមទាំងកង្វះភាពច្បាស់លាស់ទៅលើយុត្តាធិការរបស់ខ្លួន អាជ្ញាធរនេះនៅតែជាឧបករណ៍នយោបាយដែលអាចឱ្យរដ្ឋាភិបាលកណ្តាលគ្រប់គ្រងបានយ៉ាងល្អលើស្ថាប័នដទៃៗទៀតក្នុងការគ្រប់គ្រងដីធ្លី និងដំណោះស្រាយទំនាស់។ ជាការពិត អាជ្ញាធរជាតិដោះស្រាយទំនាស់ដីមិនបានផ្តល់យន្តការដោះស្រាយទំនាស់ដីធ្លីប្រកបដោយតម្លាភាព សមភាព និងអាចទទួលយកបាននោះទេ ជាពិសេសទំនាស់ពាក់ព័ន្ធនឹងប្រជាពលរដ្ឋក្រីក្រ។

គម្លាតរវាងទ្រឹស្តី និងការអនុវត្តយន្តការដោះស្រាយទំនាស់ដីធ្លី

ក្នុងការអនុវត្តជាក់ស្តែង ការប្រើប្រាស់ និងការអនុវត្តយន្តការបានរៀបរាប់មកខាងលើ នៅតែមានកម្រិតដោយសារកត្តាមួយចំនួន។ កត្តាទីមួយ ដែនសមត្ថកិច្ចដ៏ទូលំទូលាយនៃស្ថាប័នដោះស្រាយទំនាស់ និងកង្វះភាពប្រាកដប្រជាជុំវិញយុត្តាធិការនៃយន្តការនីមួយៗ ដែលត្រូវបានគេលើកឡើងថាជាប្រភពនៃការភ័ន្តច្រឡំចំពោះសក្តានុពលរបស់អ្នកប្តឹង។ [44] កត្តារារាំងដទៃទៀតរួមមាន ការទទួលបានតិចតួចនូវយន្តការដោះស្រាយទំនាស់ដោយបុគ្គលទទួលផលប៉ះពាល់ និងសហគមន៍នានា ការរៀបចំ ប្រើប្រាស់ពេលវេលាយូរ និងឧបសគ្គផ្នែកនីតិវិធី ការបង់ប្រាក់ពាក់ព័ន្ធទៅនឹងការដាក់ពាក្យបណ្តឹង។ កាលដែលមិនបានកំណត់តំលៃផ្លូវការដូចជាតំលៃពាក់ព័ន្ធទៅនឹងការដាក់ពាក្យបណ្តឹងទៅកាន់តុលាការ តំលៃធ្វើដំណើរ ប្រាក់ឈ្នួលដែលបាត់ និងជំនួយផ្លូវច្បាប់ ដែលជារឿយៗរារាំងបុគ្គលនានាក្នុងការស្វែងរកដំណោះស្រាយនៅស្ថាប័នដោះស្រាយទំនាស់ដី។ បន្ថែមលើនេះអ្នកប្តឹងបានរាយការណ៍ថា សេចក្តីសម្រេចរបស់ស្ថាប័នដោះស្រាយទំនាស់មិនស៊ីសង្វាក់គ្នា និងទទួលរងសម្ពាធនយោបាយ។[45] ម្យ៉ាងទៀត ភាពមិនឯករាជ្យនៃប្រព័ន្ធតុលាការបានធ្វើឱ្យបាត់បង់ទំនុកចិត្តទាំងស្រុងទៅលើប្រព័ន្ធដោះស្រាយទំនាស់ពីសំណាក់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយជម្លោះដីធ្លី។

ដូចបានពិភាក្សាពីខាងដើម ច្បាប់ភូមិបាលកម្ពុជាចែងថារាល់ទំនាស់ពាក់ព័ន្ធនឹងដីធ្លីដែលមិនបានចុះបញ្ជី ត្រូវតែធ្វើសវនកម្មដោះស្រាយនៅមុខគណៈកម្មាធិការសុរិយោដី។ ប៉ុន្តែតាមការអនុវត្តជាក់ស្តែង គណៈកម្មាធិការសុរិយោដីមិនបានដោះស្រាយទំនាស់នៅតាមសហគមន៍រងគ្រោះជាច្រើនអន្លើ។ គេបានដឹងពីបរាជ័យរបស់គណៈកម្មាធិការសុរិយោដីក្នុងការផ្តល់ដំណោះស្រាយត្រឹមត្រូវ និងទាន់ពេលវេលា ជាពិសេសចំពោះសហ

---

[43] ប្រភព ខាងលើ។

[44] ម៉ាក ក្រឹមឌីច្ច និងនីកូឡាស ហេនឌើស៊ុន " គ្មានប័ណ្ណកម្មសិទ្ធិ៖ សន្តិសុខនៃសិទ្ធិកម្មសិដីធ្លីនៅកម្ពុជា" ស្ពានឆ្លងព្រំដែនកម្ពុជាមជ្ឈមណ្ឌលដើម្បីសិទ្ធិលំនៅដ្ឋាន និងការបណ្តេញចេញ; សេវាជនភៀសខ្លួនយ៉េស៊ូ ឆ្នាំ (២០០៩) អាចរកបានតាម៖ http://bit.ly/1jFVjaJ។

[45] របាយការណ៍របស់អ្នកតំណាងពិសេស ឆ្នាំ២០១២។

គមន៍ដែលទទួលបានការចុះបញ្ជីដីធ្លីជាប្រព័ន្ធតិចតួច ឬសហគមន៍មិនទទួលបានការចុះបញ្ជីដីធ្លីជាប្រព័ន្ធ។[46] ម្យ៉ាងទៀត ការសិក្សាមួយរបស់ធនាគារពិភពលោកដែលធ្វើឡើងដោយមជ្ឈមណ្ឌលសម្រាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់ និង ជីអាយហ្សេត បានរកឃើញថា គណៈកម្មាធិការសុរិយោដី មានរបាយការណ៍ស្តីពីភាពល្អប្រសើរជុំវិញការដោះស្រាយជម្លោះដីតូច។ ប៉ុន្តែគណៈកម្មាធិការនេះបានខិតខំដោះស្រាយនូវករណីស្មុគ្រស្មាញនានា ជាពិសេសទំនាស់ពហុភាគី និងភាគីពាក់ព័ន្ធជាមួយរដ្ឋាភិបាល ឬទាហាន។[47] របាយការណ៍ដដែលនេះបានបំភ្លឺថា នៅពេលដែលករណីនានាស្ថិតនៅក្នុងយុត្តាធិការរបស់គណៈកម្មាធិការសុរិយោដី ភាគីទន់ខ្សោយប្រហែលមិនអាចប្តឹងបានទេ ដោយសារតែខ្វះទំនុកចិត្តចំពោះដំណើរការ និងលទ្ធផល។ ការសិក្សានេះបានរាយការណ៍ផងដែរថា ២៧ភាគរយក្នុងចំណោមភាគីនានាដែលបានស្ទង់មតិ បានរាយការណ៍ថា មានការចំណាយក្រៅផ្លូវការ ឬប្រាក់ឆ្នាន់ជាថ្នូរទទួលបានការដោះស្រាយពី*គណៈកម្មាធិការសុរិយោដី*។[48] ការសិក្សារបស់ធនាគារពិភពលោកផ្សេងទៀតបានរកឃើញថា ប្រជាពលរដ្ឋពាក់ព័ន្ធក្នុងទំនាស់ដីធ្លីសម្រេចមិនជ្រើសរើសយកវិធីប្តឹងផ្តល់ទៅ "*ស្ថាប័នយុត្តិធម៌ ដូចជា គណៈកម្មាធិការសុរិយោដី ឬតុលាការនោះទេ ព្រោះមានការចំណាយប្រាក់ ត្រូវប្រើពេលវេលា ហើយស្ថាប័នយុត្តិធម៌ទាំងនោះលម្អៀងទៅរកអ្នកមានទ្រព្យ*"។[49]

មានករណីសិក្សាចំនួនពីរខាងក្រោម ករណីមួយនៅក្នុងរាជធានីភ្នំពេញ និងករណីមួយទៀតនៅខេត្តកំពង់ចាមដែលករណីទាំងនេះបង្ហាញបញ្ហាជុំវិញភាពពុំស្មើគ្នាក្នុងទំនាស់ដីធ្លី។ ករណីទាំងពីរនេះលើកឡើងពីបរាជ័យនៃយន្តការដោះស្រាយទំនាស់ដែលមានស្រាប់ក្នុងការផ្តល់ដំណោះស្រាយដល់សហគមន៍ដែលដីធ្លីរបស់ពួកគាត់ត្រូវបានគេដណ្តើមយកតាមរយៈការចាប់ច្បាមយកដីឬសម្បទានដីសេដ្ឋកិច្ចរបស់ជនមានអំណាច។ ករណីមួយទៀតពាក់ព័ន្ធទៅនឹងទំនាស់ដីធ្លីមួយរវាងសហគមន៍កសិករ និងអ្នកជំនួញមួយរូប ដែលបង្ហាញពីភាពមិនស្មើគ្នារវាងភាគីទំនាស់ និងអប្រសិទ្ធភាពការដោះស្រាយទំនាស់របស់ក្រុមប្រឹក្សាឃុំ គណៈកម្មាធិការសុរិយោដី និងអភិបាលស្រុកទទួលបន្ទុកក្នុងការដោះស្រាយជម្លោះ។

<u>ករណីសិក្សា ១</u> ៖ សហគមន៍កសិដ្ឋានភូមិស្នឹងតូច[50]

ទីតាំង ៖ ភូមិស្នឹងតូច ឃុំកាក់ ស្រុកពញាក្រែក ខេត្តកំពង់ចាម

---

[46] ម៉ាក ក្រឹមឌីចួ និងនីកូឡាស ហោនឌើស៊ុន " គ្មានប័ណ្ណកម្មសិទ្ធិ៖ សន្តិសុខនៃសិទ្ធិកម្មសិដ្ឋីធ្លីនៅកម្ពុជា" ស្ថានធ្លងព្រំដែនកម្ពុជា មជ្ឈមណ្ឌលដើម្បីសិទ្ធិលំនៅដ្ឋាន និងការបណ្តេញចេញ; សេរាជនកៀសខ្លួនយ៉េស៊ូ ឆ្នាំ(២០០៩) អាចរកបានតាម៖ http://bit.ly/1jFVjaJ។

[47] ធានាគារពិភពលោក មជ្ឈមណ្ឌលសម្រាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់ និងជីអាយហ្សេត "តើដំណើរឆ្ពោះទៅរកស្ថាប័នយុត្តិធម៌ឬ? ការពិនិត្យមើលទៅលើការងាររបស់គណៈកម្មាធិការសុរិយោដីនៅកម្ពុជាពាក់ព័ន្ធទៅនឹងដំណោះស្រាយទំនាស់ដីធ្លី" ទំព័រ ១២ (ខែតុលា ឆ្នាំ២០០៦) អាចរកបានតាមរយៈ ៖ http://bit.ly/1n30yAW

[48] មានប្រភពដូចខាងលើ។

[49] ធានាគារពិភពលោក និងមជ្ឈមណ្ឌលដើម្បីការសិក្សាឈានមុខ "យុត្តិធម៌សម្រាប់អ្នកក្រីក្រ? ការសិក្សាពិសេសទៅលើការគ្រប់គ្រងដីធ្លីនៅថ្នាក់មូលដ្ឋាននៅកម្ពុជា" ទំព័រ៣៧ (ខែតុលា ឆ្នាំ២០០៦) អាចរកបានតាម៖ http://bit.ly/1jXlbZH។

[50] ករណីសិក្សានេះធ្វើឡើងផ្អែកទៅលើការពិភាក្សារវាង ម.ស.ម.ក និងតំណាងសហគមន៍ភូមិស្នឹងតូច ឃុំកាក់ ស្រុកពញាក្រែក ខេត្តកំពង់ចាម។

ភាគីជម្លោះ ៖ សហគមន៍កសិដ្ឋាន នៅភូមិស្នឹងតូច និងអ្នកជំនួញដ៏មានឥទ្ធិពល គឺលោក លី សុទ្ធ

សារៈតារនៃជម្លោះដីធ្លី ៖ ដីដែលមានជម្លោះនោះបានកាន់កាប់ និងបានប្រើប្រាស់ដោយសហគមន៍កសិករចាប់តាំងពីដូនតារបស់ពួកគាត់មក។ ពួកគាត់ធ្លាប់ប្រើប្រាស់ផ្លូវធ្វើដំណើរចូលទៅកាន់ដីកសិកម្ម (សិទ្ធិប្រើប្រាស់ផ្លូវ) ដោយពុំមានការរំខាន រហូតដល់ឆ្នាំ២០០៩។ ប៉ុន្តែសហគមន៍កសិករមិនមានប័ណ្ណកម្មសិទ្ធិដីធ្លី ហើយបច្ចុប្បន្នប្រើប្រាស់ផ្លូវដែលមានទំនាស់ដោយភាគីនានាក្នុងករណីនេះ។

ក្នុងខែមីនា ឆ្នាំ២០០៩ លោក សុទ្ធ ជាអ្នកជំនួញម្នាក់មកពីរាជធានីភ្នំពេញបានទិញដីតំបន់នោះ ដែលជាដីសហគមន៍កសិកររួចរាល់អាស្រ័យផល ហើយបានបិទផ្លូវ ដោយរារាំងកសិករក្នុងការធ្វើដំណើរតាមផ្លូវនោះ។ នៅពេលកសិករទាំងនោះលើកពីក្តីកង្វល់របស់ខ្លួនទៅកាន់អ្នកជំនួញរូបនោះ គាត់បានអះអាងថាគាត់មានប័ណ្ណកម្មសិទ្ធិលើដីនោះ ដូច្នេះគាត់មានសិទ្ធិធ្វើអ្វីៗគ្រប់យ៉ាង រួមទាំងបិទផ្លូវ។ បុរសជំនួញរូបនោះមិនធ្លាប់បង្ហាញកស្តុតាងបញ្ជាក់ពីកម្មសិទ្ធិដល់សហគមន៍ម្តងណាឡើយ។គាត់ថែមទាំងបានគំរាមកំហែងកសិកររដោយនិយាយថា គាត់មានមិត្តភក្តិជាអ្នកធំ ដូច្នោះគាត់មិនញញើតនឹងការប្តឹងផ្តល់នោះទេ។

សហគមន៍ស្វែងរកជំនួយពីមេឃុំ ៖ ក្នុងខែមេសា ឆ្នាំ២០០៩ សហគមន៍បានទៅរកមេឃុំឱ្យជួយ តែគាត់បានឱ្យអនុភូមិទី១ និង ទី២ ស៊ើបអង្កេតករណីនោះ។ បន្ទាប់ពីការស៊ើបអង្កេតរួចពួកគាត់សន្និដ្ឋានថា ផ្លូវដែលបិទនោះ ការពិតជាផ្លូវដែលបានប្រើប្រាស់ដោយសហគមន៍រងគ្រោះចូលទៅកាន់ដីរបស់ពួកគាត់ពិតមែន។ នៅក្នុងអំឡុងពេលកិច្ចប្រជុំមួយជាមួយសហគមន៍រងគ្រោះបានធ្វើឡើងនៅខែបន្ទាប់ក្រុមប្រឹក្សាឃុំបានស្នើអោយកសិ–ករទាំងនោះប្រើប្រាស់ផ្លូវផ្សេងមួយទៀតដើម្បីចូលទៅកាន់ដីស្រែរបស់ខ្លួន ដោយតម្រូវឱ្យពួកគាត់ធ្វើដំណើរឆ្លងកាត់ក្បាលដីនៅជាប់នោះ ដែលបានកាន់កាប់ និងកំពុងបង្កបង្កើនផលជាកម្មសិទ្ធិរបស់សមាជិកសហគមន៍ផ្សេងទៀត។

ក្រុមប្រឹក្សាឃុំ មិនបានចាត់វិធានការជួយដល់សហគមន៍ឱ្យប្រើប្រាស់ផ្លូវផ្សេងនោះទេ។ ម្យ៉ាងទៀតនោះ ការលើកសំណើអោយប្រើប្រាស់ផ្លូវផ្សេងទៀតនេះនៅតែមិនច្បាស់លាស់ថាតើវាអាចទៅបាន ឬអនុវត្តទៅបានស្របច្បាប់ ឬយ៉ាងណា។ សហគមន៍សម្រេចមិនទទួលយកផែនការផ្តល់ផ្លូវផ្សេងពីនេះ បន្ទាប់ពីមានការជូនដំណឹងថា ពួកគាត់ត្រូវចំណាយប្រាក់សម្រាប់សាងសង់ផ្លូវថ្មី។

សហគមន៍ស្វែករកជំនួយពីគណៈកម្មាធិការសុរិយោដី (ការិយាល័យអភិបាលស្រុក)

នៅក្នុង**ខែមិថុនា ឆ្នាំ២០១២** សហគមន៍កសិករបានដាក់ពាក្យបណ្តឹងទៅគណៈកម្មាធិការសុរិយោដី។ បណ្តឹងនោះត្រូវបានធ្វើសវនកម្មនៅចំពោះមុខអភិបាលស្រុក ដែលបានបង្កើតគណៈកម្មការដើម្បីស៊ើបអង្កេតជម្លោះនោះ។ ក្នុងខែសីហា ឆ្នាំ២០១២ មានការកោះឱ្យចូលរួមកិច្ចប្រជុំនៅការិយាល័យសុរិយោដីស្រុក ដែលអភិបាលស្រុកបង្កើតផែនទីមួយ ដោយបញ្ជាក់ពីទីតាំងច្បាស់លាស់នៃផ្លូវដែលមានទំនាស់នោះ។ មិនយូរមិនឆាប់មានការប្រកាសពីអភិបាលស្រុកថា បុរសជំនួញរូបនោះបានបើកផ្លូវនោះឡើងវិញហើយ។

ប៉ុន្តែនៅ**ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៣** អ្នកជំនួញរូបនោះបានកាន់កាប់ និងបានបិទផ្លូវនោះជាថ្មីម្តងទៀត ដោយបានជីកប្រឡាយទឹកព័ទ្ធជុំវិញផ្លូវ និងបានរារាំង ប្រជាពលរដ្ឋក្នុងការឆ្លងកាត់។ នៅថ្ងៃដដែលនោះ

សហគមន៍បានស្វះស្វែងរកជំនួយជាថ្មីម្តងទៀតពីអភិបាលស្រុក។ អភិបាលស្រុកបានប្រាប់ទៅសហគមន៍ថា គាត់បានដោះស្រាយបញ្ហានោះរួចរាល់ហើយ ប្រសិនបើជម្លោះនៅតែមានកើតឡើងដដែលនោះ ប្រជាកសិករគួរតែប្តឹងទៅតុលាការ។

នៅថ្ងៃ**ទី៣០ ខែសីហា ឆ្នាំ២០១៣** សហគមន៍នោះបានស្វះស្វែងរកជំនួយផ្លូវច្បាប់ពីសមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍនៅកម្ពុជា (“អាដហុក”) ដែលបានណែនាំឱ្យប្រជាពលរដ្ឋរងគ្រោះដាក់ពាក្យ បណ្តឹងទៅការិយាល័យរបស់អភិបាលស្រុក។ ផ្អែកតាមការណែនាំនេះ ប្រជាពលរដ្ឋបានដាក់ពាក្យបណ្តឹងទៅការិយាល័យនៃអភិបាលស្រុកនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៣។

នៅថ្ងៃ**ទី១៧ ខែកញ្ញា ឆ្នាំ២០១៣** ក្នុងអំឡុងពេលកិច្ចប្រជុំមួយរៀបចំឡើងនៅការិយាល័យស្រុកអនុភូមិបានស្នើឲ្យមានការបើកផ្លូវនោះឡើងវិញ ដោយពុំបានធ្វើការចោទប្រកាន់លើបុរសជំនួញរូបនោះទេ ។ ទោះបីជា អ្នកភូមិបានយល់ព្រមតាមសំណើនេះ ក៏ម្ចាស់ដីមិនបានចូលរួមក្នុងកិច្ចប្រជុំនោះ ហើយមិនបានសម្រេចផែនការច្បាស់លាស់ណាមួយឡើយ។

ស្ថានការណ៍ករណីនាពេលបច្ចុប្បន្ននេះ ដំណោះស្រាយធ្វើឡើងនៅក្រុមប្រឹក្សាថ្នាក់ឃុំ និងគណៈកម្មាធិការសុរិយោដីបាននាំទៅរកការកន្ត្រច្បាំងនៅក្នុងសហគមន៍ពីយុត្តាធិការត្រឹមត្រូវសម្រាប់សវនការលើពាក្យបណ្តឹងរបស់ពួកគេ ហើយមិនបានធ្វើការជំទាស់ប្រកបដោយប្រសិទ្ធភាពទៅលើសកម្មភាពរបស់អ្នកជំនួញរូបនោះទេ ឬក៏ធ្វើឱ្យការរស់នៅរបស់កសិករបានល្អប្រសើរនោះក៏ទេដែរ។ ប្រាកដណាស់ថា ចាប់តាំងពីឆ្នាំ២០០៩ ម្ល៉េះ អ្នកជំនួញរូបនោះបានទិញដីជាច្រើននៅក្នុងតំបន់នោះដោយធ្វើឲ្យមានប្រជាពលរដ្ឋរងគ្រោះនៅតំបន់នោះកាន់តែច្រើនឡើងដោយសារសកម្មភាពរបស់អ្នកជំនួញរូបនោះ។ សហគមន៍គ្មានជម្រើសអ្វីដទៃក្រៅពីស្វែងរកផ្លូវធ្វើដំណើរផ្សេងពីនេះ ដោយពួកគាត់ត្រូវធ្វើដំណើរយ៉ាងឆ្ងាយទៅដីស្រែរបស់ខ្លួន។

នៅក្នុង**ខែឧសភា ឆ្នាំ២០១៤** ករណីនោះត្រូវបានបញ្ជូនជាថ្មីទៅអភិបាលស្រុកដើម្បីរកដំណោះស្រាយ ហើយបច្ចុប្បន្នករណីនេះកំពុងតែព្យួរនៅថ្នាក់ស្រុក។ ជម្លោះដីធ្លីនេះបានកើតឡើងមានរយៈពេល៥ឆ្នាំមកហើយ សហគមន៍នៅតែរងចាំដំណោះស្រាយពីស្ថាប័នដោះស្រាយទំនាស់ដែលពាក់ព័ន្ធ។

ករណីទីពីរ ពាក់ព័ន្ធនឹងទំនាស់ដីធ្លីរវាងសមាជិកសហគមន៍បឹងកក់១ នៅរាជធានីភ្នំពេញ និងក្រុម*ហ៊ុនទីហរ័ណអាហរ័ណយុនសៀ* (“*ក្រុមហ៊ុន យុន សៀ*”) ដែលជាឧទាហរណ៍ជុំវិញអប្រសិទ្ធភាពនៃប្រព័ន្ធតុលាការកម្ពុជា។

<u>ករណីសិក្សា ២៖ </u>ករណីបឹងកក់១

ទីតាំង ៖ បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

ភាគីទំនាស់ ៖ ពីដំបូងឡើយមានប្រាំពីរគ្រួសារ ដោយប្រាំគ្រួសារបានទទួលយកសំណង នៅសល់គ្រួសាររងគ្រោះចំនួនពីរដែលជាភាគីនៃជម្លោះ។

សារសំខាន់នៃរឿងទំនាស់ដីធ្លី ៖ លោក លី ស្រ៊ា ខេង កូនស្រីរបស់គាត់ឈ្មោះ កញ្ញា លី ស៊ីវមិញ កូនប្រុសរបស់គាត់ និងភរិយាគាត់រស់នៅបឹងកក់១ ជាមួយនឹងគ្រួសារផ្សេងមួយទៀត។ គ្រួសារទាំងនេះបានកាន់កាប់ដីនោះចាប់តាំងពីឆ្នាំ១៩៧៩ ហើយបើទោះជាមានឯកសារបញ្ជាក់ត្រឹមត្រូវក្តី និងព្យាយាមចុះបញ្ជីដីធ្លីជាច្រើនលើកច្រើនសារ ក៏ពួកគាត់ពុំអាចចុះបញ្ជីដីធ្លីរបស់ខ្លួន ដូចមានចែងនៅក្នុងច្បាប់កូមិបាលនោះទេ។

គ្រួសារទាំងនេះបានកាន់កាប់ដីជាប់នឹងការិយាល័យក្រុមប្រឹក្សាឃុំ និងគណបក្សប្រជាជន ដែលកាលពីឆ្នាំ២០១៣ សាលាក្រុងភ្នំពេញបានចេញលិខិតមួយច្បាប់បញ្ជាក់ថា ដីដែលមានទំនាស់នោះគឺជាកម្មសិទ្ធិរបស់រដ្ឋ។ រដ្ឋាភិបាលមានបំណងធ្វើការផ្លាស់ប្តូរដីនោះជាមួយក្រុមហ៊ុន ឃុន សៀ ដែលមានបំណងធ្វើការអភិវឌ្ឍន៍នៅលើដីនោះ។ ចាប់ពីពេលនោះមកគ្រួសារទាំងនោះបានជាប់នៅក្នុងទំនាស់ដីធ្លីដ៏អូសបន្លាយជាយូរមកហើយនោះ។ លោក ឃុន សៀ គឺជាសេដ្ឋីអចលនៈទ្រព្យដ៏ស្តុកស្តម្ភម្នាក់ ដែលជាម្ចាស់ក្រុមហ៊ុន ឃុន សៀ។ ដៃគូរជំនួញរបស់គាត់ គឺ លោក យឹម លាង ប្រធានអង្គភាពកងអង្គរក្សរបស់ប្រធានព្រឹទ្ធសភា។

ក្តីបារម្ភពីសន្តិសុខរបស់សមាជិកសហគមន៍រងគ្រោះ ៖ ក្រុមហ៊ុនបានជួលកងសន្តិសុខឱ្យគំរាមកំហែង និងយាយីគ្រួសារដែលមិនព្រមចាកចេញពីដីនោះ។ កងសន្តិសុខរស់នៅលើទីកន្លែងដែលសព្វថ្ងៃនេះជាអាគារទទេរបស់គណបក្សប្រជាជន។

ចាប់តាំងពី**ខែឧសភា ឆ្នាំ២០១៣** កញ្ញា លី ស៊ីវមិញ និងគ្រួសាររបស់នាងបានរងការគំរាមកំហែង និងរងការវាយដំជាបន្តបន្ទាប់ជាច្រើនលើកច្រើនសាររួមទាំងរងការដុតផ្ទះសម្បែង ការវាយដំលើរូបរាងកាយ ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ និងត្រូវបានគេបោះពស់វែកចំនួនបីក្បាលចូលទៅក្នុងផ្ទះ។ បន្ថែមពីនេះ សមាជិកនៃគ្រួសារដែលនៅសេសសល់ត្រូវបានចោទប្រកាន់នៅថ្ងៃទីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៣ ពីបទ(*លួចដោយមានស្ថានទម្ងន់ទោស*និងត្រូវបានតុលាការកោះហៅជាច្រើនសារដើម្បីសាកសួរពាក់ព័ន្ធពាក្យបណ្តឹងដែលបានប្តឹងដោយលោក ឃុន សៀ។

ពាក្យបណ្តឹងបានប្តឹងទៅតុលាការ៖

កាលពីថ្ងៃទី ២១ ខែមិថុនា ឆ្នាំ២០១៣ កញ្ញា លី ស៊ីវមិញ បានដាក់ពាក្យបណ្តឹងទៅតុលាការក្រុងភ្នំពេញ ដោយចោទប្រកាន់ទៅលើជនសង្ស័យចំនួន១០នាក់ពីបទបំផ្លិចបំផ្លាញលំនៅដ្ឋាន។ យោងតាមពាក្យបណ្តឹងនោះ កញ្ញាបានប្តឹងអ្នកទាំង១០នាក់នោះពីបទ "*ហិង្សាដោយចេតនា និងការបំផ្លិចបំផ្លាញ និងការធ្វើឱ្យខូចខាតទ្រព្យសម្បត្តិដោយចេតនាមានស្ថានទម្ងន់ទោស*"។ កញ្ញាមិនទាន់ទទួលបានការជូនដំណឹងណាមួយពីតុលាការនៅឡើយទេ។

នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣ លោក លី ស្រ៊ាខេង បានដាក់ពាក្យបណ្តឹងទៅកាន់តំណាងអយ្យការនៃសាលាដំបូងរាជធានីភ្នំពេញប្តឹងលោក ឃុន សៀ និងអតីតកងសន្តិសុខចំនួន១០នាក់របស់ក្រុមហ៊ុន។ លោកបានលើកឡើងពីការយោយីពីសំណាក់កងសន្តិសុខដល់គ្រួសាររបស់លោកដែលជាជនរងគ្រោះពីការប៉ុនប៉ងមនុស្សឃាត និងការរំលោភបំពានជាបន្តបន្ទាប់ទៅលើសិទ្ធិដីធ្លីរបស់លោក។ នៅថ្ងៃ**ទី០៦ ខែវិច្ឆិកា ឆ្នាំ**

២០១៣ ព្រះរាជអាជ្ញាបានរកឃើញភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ដើម្បីបន្តសំណុំរឿងនេះ និងបានបញ្ជូនបន្តទៅអយ្យការស៊ើបសួរដើម្បីចាប់ដំណើរការនីតិវិធី។

នៅថ្ងៃទី**១០ ខែវិច្ឆិកា ឆ្នាំ២០១៣** កញ្ញា លី ស៊ីវមិញ បានប្តឹងជំទាស់ទៅនឹងការទាមទារដីនោះដោយ*ក្រុមហ៊ុនយុនសៀ*ទៅកាន់សាលាដំបូងរាជធានីភ្នំពេញ។

ការចោទប្រកាន់លើសមាជិកសហគមន៍ ៖

នៅថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០១៣ ការិយាល័យព្រហ្មទណ្ឌកម្រិតធ្ងន់នៃក្រសួងមហាផ្ទៃបានកោះហៅសមាជិក៤រូប នៃគ្រួសារចំនួនបីពាក់ព័ន្ធនឹងបណ្តឹងរបស់ក្រុមហ៊ុន ឃុន សៀ ចោទប្រកាន់ពួកគេពីបទ *"រឹបអូសយកទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន"*។ បន្ទាប់ពីការសួរនាំរួច ពួកគេត្រូវបាននរគបាលដាក់ខ្នោះ និងបង្ខំឱ្យចូលទៅក្នុងឡានដឹកមកកាន់តុលាការក្រុងភ្នំពេញ។ នៅថ្ងៃដដែលនោះ ពួកគេត្រូវដោះលែង និងបានចោទពីបទ *"លួចដោយមានស្ថានទម្ងន់ទោស"* (មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ)។

នៅក្នុងលិខិតមួយច្បាប់ចុះ**ថ្ងៃទី ០៨ ខែឧសភា ឆ្នាំ២០១៤** លោក លី ប៊ុនហៀង និងកញ្ញា លី ស៊ីវមិញ (បងស្រី និងប្អូនប្រុស) ត្រូវបានតុលាការកោះឱ្យចូលបង្ហាញខ្លួននៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤ តាមការចោទប្រកាន់ពីបទ *"បំផ្លិចបំផ្លាញ និងរឹបអូសយកទ្រព្យសម្បត្តិរបស់អ្នកដទៃដោយហិង្សា"*។ ក្នុងបណ្តឹងស្រដៀងគ្នានេះ អ្នកស្រី សុខ ហ៊ុច ក៏ត្រូវបានតុលាការកោះឱ្យចូលខ្លួនឆ្លើយបំភ្លឺនៅថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ២០១៤ ផងដែរ។[51]

នៅថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០១៤ លោក ឃុន សៀ បានដាក់ពាក្យបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងលោក លី ស្រ៊ាងខេង អ៊ុក សុខឃៀង និងភរិយារបស់លោក អ្នកស្រី នូ វន្នី និងអ្នកស្រី សុខ ហ៊ុច ក្នុងគោលបំណងដើម្បីឱ្យពួកគេចេញពីដីដែលគាត់អះអាងថាជាកម្មសិទ្ធិរបស់គាត់។ [52] បន្ទាប់មកតុលាការបានកោះហៅអ្នកទាំង ៤នាក់នោះដើម្បីសាកសួរនៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៤ ប៉ុន្តែមេធាវីរបស់ លោក លី ស្រ៊ាខេង បានស្នើសុំឱ្យពន្យាពេល។ មិនមានការកំណត់កាលបរិច្ឆេទថ្មីនៅឡើយនោះទេ។

ករណីសិក្សានេះបង្ហាញច្បាស់ថា តុលាការមិនត្រឹមតែមិនបានដោះស្រាយទំនាស់ដីធ្លី និងការពារគ្រួសារទាំងនោះមិនឱ្យមានការខាតបង់នោះទេ តែថែមទាំងកំពុងត្រូវអ្នកមានស្តុកស្តម្ភដែលមានឥទ្ធិពលប្រើប្រាស់ដើម្បីយាយីទៅលើបុគ្គលទាំងឡាយណាដែលព្យាយាមការពារដីធ្លីរបស់ខ្លួនពីការដណ្តើមយក។

តាមរយៈការបង្ហាញករណីសិក្សានេះ យន្តការដោះស្រាយទំនាស់មិនបានផ្តល់នូវដំណោះស្រាយគ្រប់គ្រាន់ក្នុងករណីទំនាស់ដីធ្លីនោះទេ និងជាហេតុកាន់តែធ្វើឱ្យមានស្ថានភាពក្រីក្រ និងធ្ងន់ធ្ងរឡើងដល់សង្គម និង

---

[51] ម៉ាក ក្រឹមឌីច្ច និងនីកូឡាស ហោនឌើស៊ុន " គ្មានប័ណ្ណកម្មសិទ្ធិ៖ សន្តិសុខនៃសិទ្ធិកម្មសិទ្ធិដីធ្លីនៅកម្ពុជា" ស្ថានឆ្លងព្រំដែនកម្ពុជាមជ្ឈមណ្ឌលដើម្បីសិទ្ធិលំនៅដ្ឋាន និងការបណ្តេញចេញ; សៅជនភៀសខ្លួនយ៉េស៊ូ ឆ្នាំ (២០០៩) អាចរកបានតាម៖ http://bit.ly/1jFVjaJ។

[52] សូមមើលកំណត់ត្រាសង្ខេបរបស់ ម.ស.ម.ក "ការប្រើកម្លាំងហួសហេតុប្រឆាំងលើបាតុករក្នុងឆ្នាំ២០១៣ នៅកម្ពុជា" (ថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៤) អាចរកបានតាមរយៈ ៖ http://bit.ly/1jFVjaJ។

សេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋរងគ្រោះ។ បរិយាកាសនាពេលបច្ចុប្បន្នជុំវិញដំណើរការដោះស្រាយទំនាស់ដីធ្លីគឺត្រូវបានបង្ហាញឡើងតាមរយៈការគំរាមកំហែង ការបំពានអំណាច និងអំពើពុករលួយ។ ការពុំទទួលបានយន្តការដោះស្រាយទំនាស់គ្រប់គ្រាន់ និងយុត្តិធម៌ បាននាំឱ្យបុគ្គល និងសហគមន៍នានាធ្វើការជំទាស់ចំពោះសម្បទានដី និងបានអំពាវនាវឱ្យរដ្ឋាភិបាលការពារដីធ្លីរបស់ពួកគាត់ និងប្រកពនៃការចិញ្ចឹមជីវិត។ ជាពិសេស សហគមន៍ពាក់ព័ន្ធក្នុងទំនាស់ដីធ្លី កំពុងងាកទៅរកការតវ៉ា ហើយធ្វើសកម្មភាពដោយផ្ទាល់ដើម្បីប្រឆាំងនឹងសម្បទានដី ការចាប់ច្បាមយកដីធ្លី និងជាហេតុធ្វើឱ្យមានការផ្លាស់ទី។ អាជ្ញាធររដ្ឋបានឆ្លើយតបតាមរយៈការចោទប្រកាន់ថ្នាក់ដឹកនាំសហគមន៍ និងសកម្មជននានាពីបទល្មើសព្រហ្មទណ្ឌរួមមាន បទញុះញង់ បទបរិហារកេរ្តិ៍ បទធ្វើឱ្យខូចខាត និងបទវាយប្រហារជាដើម។ ក្នុងករណីភាគច្រើន គ្មានកស្តុតាង ឬមានកស្តុតាងមិនគ្រប់គ្រាន់ដាក់បន្ទុកលើពួកគេ។[53] កំណត់ត្រាសង្ខេបរបស់ ម.ស.ម.ក បានចេញផ្សាយនៅថ្ងៃទី ០៣ ខែមករា ឆ្នាំ២០១៤ ពន្យល់បន្ថែមលើករណីនេះថា *"ការរកឃើញរបស់ ម.ស.ម.ក បង្ហាញថាខណៈដែលបាតុកម្មនានានៅកម្ពុជាអាចពាក់ព័ន្ធទៅនឹង ផលប្រយោជន៍ជាច្រើន បាតុកម្មពាក់ព័ន្ធនឹងច្បាប់ការងារ និងសិទ្ធិដីធ្លី តែងត្រូវប្រឈមនឹងអំពើហិង្សាច្រើនជាងគេ"*។[54]

សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ប្រជាពលរដ្ឋកម្ពុជាត្រូវបានបង្ខំទីលំនៅ ឬបានប្រឈមទៅនឹងការផ្លាស់ប្តូរលំនៅដ្ឋានដោយសារតែសម្បទានដីសេដ្ឋកិច្ច និងការចាប់ច្បាមយកដីធ្លី ដោយពុំទទួលបានដំណោះស្រាយ និងទទួលបានប្រយោជន៍ពីយន្តការដោះស្រាយទំនាស់ដីធ្លីនោះទេ។ បរាជ័យក្នុងការការពារ និងការផ្តល់ដំណោះស្រាយតាមផ្លូវច្បាប់ ជាពិសេសចំពោះជនក្រីក្រ និងសហគមន៍នានាដែលមិនទទួលបានអត្ថប្រយោជន៍ ជាការរំលោភបំពានដ៏ច្បាស់លើរដ្ឋធម្មនុញ្ញកម្ពុជាដែលធានាថា *"ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ"*។[55] ការពុំទទួលបានយន្តការប្រកបដោយប្រសិទ្ធភាព និងឯករាជ្យនៅក្នុងដំណោះស្រាយទំនាស់ដីធ្លីនោះ នាំឱ្យសហគមន៍ក្រីក្រ និងសហគមន៍ដែលងាយរងគ្រោះ នៅតែប្រឈមនឹងបញ្ហាដកហូតដីធ្លីរបស់ពួកគាត់ និងកំពុងតែត្រូវបានគេផ្លាស់ប្តូរលំនៅដ្ឋានជាមួយនឹងនីទណ្ឌភាព។

ចំពោះករណីទំនាស់ដីធ្លីកម្រិតខ្ពស់ និងកង្វះសន្តិសុខផ្នែកកម្មសិទ្ធិ ការបំពេញមុខងារដ៏មានប្រសិទ្ធភាពលើយន្តការដោះស្រាយទំនាស់ដីធ្លីនេះគឺជាមូលដ្ឋានក្នុងការទទួលបានសិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋាននៅកម្ពុ

---

[53] ម៉ាក ក្រឹមឌីច្ច និងនីកូឡាស ហេនឌើស៊ុន " គ្មានប័ណ្ណកម្មសិទ្ធិ៖ សន្តិសុខនៃសិទ្ធិកម្មសិទ្ធិដីធ្លីនៅកម្ពុជា" ស្ថានឆ្លងព្រំដែនកម្ពុជាមជ្ឈមណ្ឌលដើម្បីសិទ្ធិលំនៅដ្ឋាន និងការបណ្តេញចេញ; សេវាជនភៀសខ្លួនយើស៊ូ ឆ្នាំ(២០០៩) អាចរកបានតាម៖ http://bit.ly/1jFVjaJ។

[54] សូមមើលកំណត់ត្រាសង្ខេបរបស់ ម.ស.ម.ក "ការប្រើកម្លាំងហួសហេតុប្រឆាំងលើបាតុករក្នុងឆ្នាំ២០១៣ នៅកម្ពុជា" (ថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៤) អាចរកបានតាមរយៈ ៖ http://bit.ly/1jFVjaJ។

[55] រដ្ឋធម្មនុញ្ញ មាត្រា ៣១ អាចរកបានតាមរយៈ ៖, http://bit.ly/Smzd1q។

ជា និងធ្វើឱ្យប្រសើរដល់ការទទួលបានយុត្តិធម៌សម្រាប់សហគមន៍នានា។ ព្រោះហេតុនេះ ម.ស.ម.ក ផ្តល់ជូននូវអនុសាសន៍នានាដូចខាងក្រោមដល់រដ្ឋាភិបាល ៖

- ជានាដល់ឯករាជ្យភាពនៃប្រព័ន្ធតុលាការ និងយន្តការដោះស្រាយទំនាស់ដីធ្លី,
- ជានាដល់ការទទួលបានយន្តការដោះស្រាយទំនាស់ស្មើភាពគ្នាដល់គ្រប់ភាគីមានទំនាស់ដីធ្លី,
- លើកកម្ពស់ការយល់ដឹងពីយន្តការដោះស្រាយទំនាស់ និងករណីយកិច្ច ព្រមទាំងការទទួលខុសត្រូវរបស់គណៈកម្មាធិការសុរិយោដីគ្រប់លំដាប់ថ្នាក់នៅទូទាំងប្រទេសបង្កើតនីតិវិធីជ្រើសរើសប្រកបដោយតម្លាភាពដើម្បីសម្រាំងយកអ្នកធ្វើសេចក្តីសម្រេចក្នុងការដោះស្រាយទំនាស់ រួមទាំងការកំណត់ និងចែងពីលក្ខខណ្ឌតម្រូវសមស្របពាក់ព័ន្ធនឹងកម្រិតនៃការអប់រំ និងលក្ខណៈសម្បត្តិ,
- ព្រាងនូវគោលនយោបាយស្តីពីទំនាស់ផលប្រយោជន៍ ដោយដាក់ចេញឱ្យអនុវត្តន៍មុនការតែងតាំងសមាជិកថ្មីណាមួយសម្រាប់ស្ថាប័នដោះស្រាយទំនាស់,
- បង្កើតយន្តការដោះស្រាយបណ្តឹងពាក់ព័ន្ធនឹងលក្ខខណ្ឌការងារ ប្រកបដោយអត្ថន័យសម្រាប់អ្នកទាំងឡាយដែលជឿថាបណ្តឹងរបស់ខ្លួននោះត្រូវបានដោះស្រាយដោយលម្អៀង និងអយុត្តិធម៌ពីសំណាក់ស្ថាប័នដោះស្រាយទំនាស់ និង,
- យន្តការដោះស្រាយទំនាស់ដូចជាអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី គណៈកម្មាធិការសុរិយោដីគួរចេញនូវរបាយការណ៍ប្រចាំឆ្នាំអំពីសកម្មភាពរបស់ខ្លួន។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក វណ្ណ សុផាត អ្នកសម្របសម្រួលគម្រោងកំណែទម្រង់ដីធ្លីរបស់ ម.ស.ម.ក តាមរយៈទូរសព្ទ ៖ + ៨៥៥ (០) ១២ ៩៤ ១២ ០៦ ឬតាមរយៈអ៊ីម៉ែល ៖ vann.sophath@cchrcambodia.org ឬ លោកស្រី ហ្សូលីយ៉ែត រ៉ូស្សេឡត ទីប្រឹក្សា ម.ស.ម.ក តាមទូរសព្ទ ៖ +៨៥៥ (០) ១៥ ៣៥០ ៦២០ ឬអ៊ីម៉ែល ៖ julietterousselot@cchrcambodia.org។